ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៤១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការតម្លើងតួនាទី ភារកិច្ច របស់សេនាធិការដ្ឋាន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ថ្នាក់ស្មើនាយកដ្ឋានកណ្តាល

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ១៦អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ២៧អនក្រ.បក ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០២ ស្តីពីការបង្កើតអគ្គស្នងការដ្ឋាននគរបាលជាតិ នៃក្រសួងមហាផ្ទៃ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានតម្លើងតួនាទី ភារកិច្ចរបស់សេនាធិការដ្ឋាន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ថ្នាក់ស្មើនឹងនាយកដ្ឋានកណ្តាល ។

**មាត្រា២ :** សេនាធិការដ្ឋាន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ដឹកនាំ គ្រប់គ្រងដោយប្រធាន ០១រូប និងមានអនុប្រធានមួយចំនួនជាជំនួយការ ។

**មាត្រា៣ :** រចនាសម្ព័ន្ធសេនាធិការដ្ឋាន រួមមាន :

១-នាយកដ្ឋានរដ្ឋបាលទូទៅ

២-នាយកដ្ឋានសរុប-ផែនការ

៣-នាយកដ្ឋានកិច្ចការបរទេស

៤-អង្គភាពតម្រួតបទបញ្ជា

៥-ស្នងការដ្ឋានហិរញ្ញកិច្ច និងភស្តុភារ

៦-នាយកដ្ឋានវិទ្យុទាក់ទង

៧-នាយកដ្ឋានបំព័ន្ធអក្សរ

**មាត្រា៤ :** តួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់សេនាធិការដ្ឋាន នាយកដ្ឋាន អង្គភាព ស្នងការដ្ឋាន និងការិយាល័យចំណុះ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៥ :** បទបញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ ឧសភា ឆ្នាំ២០០៧

សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា៦
- ឯកសារ-កាលប្បវត្តិ

## រចនាសម្ព័ន្ធរបស់សេនាធិការដ្ឋាន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ

ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ៤៩ អនក្រ.បក
ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៧

